# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញបំពេញបេសកកម្ម នៅសហរដ្ឋអាមេរិក

កាលពីថ្ងៃទី១១-២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានដឹកនាំគណៈប្រតិភូទៅចូលរួមពិធីអបអរសាទរខួបលើកទី ១០ នៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌទ្វេភាគីរវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងធ្វើការបញ្ចុះបញ្ចូល សមាជិកព្រឹទ្ធសភា សមាជិកសភា មន្ត្រីរដ្ឋាភិបាល អង្គការក្រៅ រដ្ឋាភិបាល និងវិស័យឯកជន សហរដ្ឋអាមេរិក ដើម្បីជំរុញសុំឱ្យមានការគាំទ្រ ដល់ការលើកលែងពន្ធនូវទំនិញ ពីបណ្តាប្រទេសក្រីក្រ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងវ៉ាស៊ីតោនឌីស៊ី សហរដ្ឋអាមេរិក ។

ក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានថ្លែងបញ្ជាក់ពីការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការពុះពាររាល់ការលំបាកគ្រប់បែបយ៉ាងដើម្បីអនុវត្តគោលនយោបាយពាណិជ្ជកម្មផ្សាភ្ជាប់លក្ខខណ្ឌការងារក្នុងឧស្សាហកម្មកាត់ដេរ គោលនយោបាយដែលថ្មីពុំមានអ្នកស្គាល់ ហើយគ្មានប្រទេសណាមួយក្នុងលោកដែលហ៊ានចុះហត្ថលេខាព្រមព្រៀងជាមួយសហរដ្ឋអាមេរិក ក្នុងរយៈពេល១០ឆ្នាំមុន ប៉ុន្តែកម្ពុជាយល់ព្រមទទួលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ពេលនេះកម្ពុជាកំពុងត្រូវបានអន្តរជាតិទទួលស្គាល់ ជាពិសេសសង្គមអាមេរិកតែម្តង។ បច្ចុប្បន្នគោលនយោបាយនេះត្រូវបានគេយកគំរូតាមកម្ពុជា មានប្រទេស វៀតណាម ប្រទេស ហ្សកដានី ប្រទេស ឡេតសូតូ និង ប្រទេសមួយចំនួនទៀតនៅអាហ្វ្រិកបានយល់ព្រម ដើរតាមគោលនយោបាយនេះ ។

ក្រៅពីកិត្តិស័ព្ទរបស់កម្ពុជា ត្រូវបានការទទួលស្គាល់អ្នកបញ្ជាទិញធំៗបានប្រកាសក្នុងអង្គពិធីថានឹងបន្ថែមការដាក់បញ្ជាទិញមកកម្ពុជាទៀត ដើម្បីជួយឧស្សាហកម្មកាត់ដេរដែលគោរពលក្ខខណ្ឌការងារកំពុងជួបការលំបាក។ មិនតែប៉ុណ្ណោះ ពួកគាត់បានសរសេរញត្តិគាំទ្រគោលនយោបាយរបស់កម្ពុជា ជូនសភាតំណាងនិងព្រឹទ្ធសភាអោយផ្តល់ភាពអនុគ្រោះពន្ធមកកម្ពុជា នៅឆ្នាំ២០១០ នៅពេលដែលសភាទាំងពីររៀបចំកំណែទំរង់គំរោងអនុគ្រោះពន្ធរបស់ខ្លួន។ លើសពីនោះទៀតក្រុមអ្នកបញ្ជាទិញសំខាន់ៗបានបញ្ចេញវិភាគទានរបស់ខ្លួនមួយលានដុល្លារសហរដ្ឋអាមេរិក ដើម្បីជូនដល់អង្គការ **ILO** ដើម្បីគាំទ្រគំរោងការពារសិទ្ធិកម្មករនេះក្នុងសកលលោកបន្តទៀត ។

ឆ្លៀតក្នុងបេសកកម្មនោះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានដឹកនាំគណៈប្រតិភូ ចូលរួមក្នុងវេទិកា ប្រមូលសក្ខីកម្មរបស់គណៈកម្មាធិការមធ្យោបាយ និងនិតិវិធី **(Ways and Means Committee)** ដើម្បីផ្តល់ឯកសារភស្តុតាង និងផ្តល់បទអន្តរាគមន៍ជូនសភា សំរាប់ជាមូលដ្ឋានពិចារណារៀបចំពង្រាងច្បាប់កំណែទំរង់គំរោងអនុគ្រោះពន្ធពីឆ្នាំ២០១០-២០១៩ ខាងមុខនេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** មានការយកចិត្តទុកដាក់ខ្ពស់ក្នុងការបញ្ចុះបញ្ចូលសមាជិកសភា តំណាង និងព្រឹទ្ធសភាដែលមានឥទ្ធិពលខ្លាំង អោយយល់ព្រមបោះឆ្នោតគាំទ្រពង្រាងច្បាប់អនុគ្រោះពន្ធសំរាប់ប្រទេសក្រីក្រ ដែលមានកម្ពុជាផងដែរ ដើម្បីមានឱកាសស្រោចស្រង់ឧស្សាហកម្មកម្ពុជាដែលកំពុងជួបវិបត្តិ។ បន្ថែមសម្ពាធទៅលើការអនុម័តច្បាប់ថ្មីនៅ ឆ្នាំ២០១០ នេះ ក្រៅពីមានសំលេងគាំទ្រពីអ្នកបញ្ជទិញខាងលើឯកឧត្តម ទេសរដ្ឋមន្ត្រីក៏បានចូលរួមថ្លែងក្នុងវេទិកា ស្តីពីតួនាទីនយោបាយពាណិជ្ជកម្មសហរដ្ឋអាមេរិក ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ពិភពលោកនៅវិមានកាពីតូល ក្រោមអធិបតីភាពលោកជីម៉ាកដឺម៉ុត សភាតំណាងរាស្ត្រដែលមានការគាំទ្រកម្ពុជាជាបន្តបន្ទាប់ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានជួបពិភាក្សាការងារជាមួយអង្គការសាជីវកម្មហិរញ្ញវត្ថុ និងធនាគារពិភពលោក ដើម្បីផ្លាស់ប្តូរយោបលគ្នាលើស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងដំណាក់កាលវិបត្តិ ក៏ដូចជាស្ថានភាពឧស្សាហកម្មកាត់ដេរដែលកំពុងធ្លាក់ចុះ ហើយរិះរកលទ្ធភាព ហិរញ្ញប្បទាន ជួយដល់ឧស្សាហកម្មធនតូច និងមធ្យម ដែលអាចមានលទ្ធភាពពង្រឹងសមត្ថភាពរបស់ខ្លួន និងដែលអាចចូលរួមក្នុងស្តារឡើងវិញនូវវិបត្តិសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។